ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តសៀមរាប

សំណុំរឿងរដ្ឋប្បវេណី
លេខ ១៧២
ចុះថ្ងៃទី២៧-០៤-២០២០
សាលក្រមរដ្ឋប្បវេណី
លេខ: ២៧ -ឃ-
ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២០

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តសៀមរាប

បានបញ្ចប់ការទាញហេតុផលផ្ទាល់មាត់ នៅថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២០ ប្រកាសសាលក្រម ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២០ ដោយមានសមាសភាព:

**ចៅក្រម**

-លោក [redacted] ចៅក្រមសាលាដំបូងខេត្តសៀមរាប

**ក្រឡាបញ្ជី**

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តសៀមរាប

**រវាងសហដើមចោទ**

១-ឈ្មោះ [redacted] ចំប៉ា ភេទស្រី អាយុ២៧ឆ្នាំ ទីកន្លែងកំណើតនៅ[redacted] ទីលំនៅបច្ចុប្បន្ននៅ[redacted] ឪពុកឈ្មោះ [redacted] បឿន (រស់) ម្តាយឈ្មោះ [redacted] ពៅ (រស់)។

២- ឈ្មោះ [redacted] ពៅ ភេទស្រី អាយុ៥៥ឆ្នាំ ទីកន្លែងកំណើត[redacted] ទីលំនៅបច្ចុប្បន្ននៅ[redacted] ប្តីឈ្មោះ [redacted] បឿន មានកូន០៤នាក់ ឪពុកឈ្មោះ [redacted] ប្រេម (ស្លាប់) ម្តាយឈ្មោះ [redacted] អេង (ស្លាប់)។

ដោយមានលោកស្រី [redacted] អត្តលេខ ២០៤៤T ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទឈ្មោះ [redacted] ចំប៉ា និងឈ្មោះ [redacted] ពៅ នៅការិយាល័យមេធាវី[redacted]។

និងចុងចំលើយ ឈ្មោះ [redacted] ស្រីពេជ្រ ភេទស្រី អាយុ២៥ឆ្នាំ ទីលំនៅបច្ចុប្បន្ននៅ[redacted]។

ដោយមានលោក [redacted] អត្តលេខ ២០០៥T ជាមេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយឈ្មោះ [redacted] ស្រីពេជ្រ មានការិយាល័យក្រុមមេធាវី [redacted] អាសយដ្ឋាន[redacted]។

**អង្គហេតុ និងចំណុចវិវាទ**

១-សាលក្រមដែលទាមទារដោយដើមចោទ៖

ក-បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] ស្រីពេជ្រ សងប្រាក់ចំនួន ៨៦ ៥០០$ (ប្រាំបីម៉ឺនប្រាំមួយ



Scanned with CamScanner

ពាន់ប្រាំរយ)ដុល្លារអាមេរិក ឱ្យដើមចោទឈ្មោះ [redacted] ចំប៉ា ។

ខ-បង្គាប់ឱ្យចុងចម្លើយសងការប្រាក់ចំនួន៥% ក្នុងមួយខែគណនាលើប្រាក់ដើមចំនួន ៨៦ ៥០០ (ប្រាំបីម៉ឺនប្រាំមួយពាន់ប្រាំរយ)ដុល្លារអាមេរិក ដោយចាប់គិតពីថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៩ រហូតដល់ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៩។

គ-បង្គាប់ឱ្យចុងចម្លើយសងសំណងការខូចខាត ចំពោះការយឺតយ៉ាវ ដែលមិនបានសងប្រាក់ដើមតាមការកំណត់ ចំនួន ២៧% ក្នុងមួយឆ្នាំ គណនាលើប្រាក់ដើមចំនួន ៨៦ ៥០០ ដុល្លារអាមេរិក ដោយចាប់គិតពីថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៩ រហូតដល់ថ្ងៃសងប្រាក់ដើមគ្រប់ចំនួន ។

ឃ-បង្គាប់ឱ្យចុងចម្លើយសងសំណងការខូចខាត និងជម្ងឺចិត្តចំនួន១២០.០០០.០០០៛ (មួយរយម្ភៃលាន)រៀល ឱ្យដើមចោទ ។

ង- ឱ្យចុងចម្លើយទទួលបន្ទុកប្រាក់ប្រដាប់ក្តី ។

ច- ប្រកាសអនុវត្តបណ្តោះអាសន្នលើចំណុច ក,ខ,គ ។

**២-ការពន្យល់ត្រួសៗអំពីរឿងក្តី៖**

នៅអំឡុងឆ្នាំ២០១៨ និងឆ្នាំ២០១៩ ចុងចម្លើយឈ្មោះ [redacted] ស្រីពេជ្រ បានមកខ្ចីប្រាក់ពីសហដើមចោទឈ្មោះ [redacted] ចំប៉ា និងឈ្មោះ [redacted] ពៅ ជាច្រើនលើក ដោយមានការខ្ចីសងៗជាបន្តបន្ទាប់ ស្រាប់តែខ្ចីប៉ុន្មានលើកចុងក្រោយចុងចម្លើយឈ្មោះ [redacted] ស្រីពេជ្រ ក៏ឈប់សងមកឱ្យសហដើមចោទតែម្តង ដោយប្រាក់ដែលចុងចម្លើយមិនទាន់បានសងមកឱ្យសហដើមចោទមានចំនួនសរុប ៨៦ ៥០០ (ប្រាំបីម៉ឺនប្រាំមួយពាន់ប្រាំរយ)ដុល្លារអាមេរិក។ ក្នុងការខ្ចីប្រាក់ខាងលើនេះ គូភាគីបានធ្វើកិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៩ ផងដែរ ហើយនៅក្នុងកិច្ចសន្យាបានកំណត់អត្រាការប្រាក់ចំនួន ៥%ក្នុងមួយខែ និងកំណត់ថ្ងៃសងនៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៩ ពេលដល់ថ្ងៃកំណត់ត្រូវសងចុងចម្លើយបានគេចវេសមិនព្រមសងរហូតដល់បច្ចុប្បន្ន។

៣.លោកស្រី [redacted] និងលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទឈ្មោះ [redacted] ចំប៉ា និងឈ្មោះ [redacted] ពៅ បានថ្លែងការណ៍ថា ខ្លួនសូមរក្សាការទាមទារដូចមាននៅក្នុងសេចក្តីថ្លែងការណ៍នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល កាលពីថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២០ ទុកជាបានការរំលែល។ កន្លងមក ចុងចម្លើយបានខ្ចីប្រាក់ដើមចោទ ជាបន្តបន្ទាប់ជាច្រើន គឺ ៖

- នៅថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០១៨ ខ្ចីចំនួន ១០.០០០$ ។
- នៅថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៩ ខ្ចីចំនួន ៥.០០០$ ។
- នៅថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៩ ខ្ចីចំនួន ២.០០០$ ។
- នៅថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៩ ខ្ចីចំនួន ៣.៥០០$ ។
- នៅថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៩ ខ្ចីចំនួន ៧.០០០$ ។
- នៅថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៩ ខ្ចីចំនួន ១.៥០០$ ។
- នៅថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៩ ខ្ចីចំនួន ៥.០០០$ ។



Scanned with CamScanner

- នៅថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៩ ខ្ចីចំនួន ៤.៥០០$ ។
- នៅថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៩ ខ្ចីចំនួន ៥.០០០$ ។
- នៅថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៩ ខ្ចីចំនួន ៧.០០០$ ។
- នៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៩ ខ្ចីចំនួន ១០.០០០$ ។
- នៅថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៩ ខ្ចីចំនួន ២០.០០០$ ។
- នៅថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១៩ ខ្ចីចំនួន ១៤.០០០$ ។
- នៅថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៩ ខ្ចីចំនួន ៤.០០០$ ។
- នៅថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៩ ខ្ចីចំនួន ៣.០០០$ ។

សរុបប្រាក់ដែលបានខ្ចីខាងលើនេះមានចំនួន ១០១.៥០០$ ប្រាក់នេះចុងចម្លើយបានសង លើកទី ១ នៅថ្ងៃ ទី ២៧ ខែកុម្ភៈ ឆ្នាំ ២០១៩ ចំនួន ១០.០០០$ និងនៅថ្ងៃទី ០៤ ខែមីនា ឆ្នាំ២០១៩ សងបាន ៥ ០០០$ នៅសល់ប្រាក់ចំនួន ៨៦. ៥០០ (ប្រាំបីម៉ឺនប្រាំមួយពាន់ប្រាំរយ) ដុល្លារអាមេរិក ដែលចុងចម្លើយមិនទាន់បានសងឱ្យដើមចោទវិញ។ ក្រៅពីប្រាក់កម្ចីខាងលើនេះ គឺមានការខ្ចីជាច្រើនលើកទៀត តែប្រាក់ដែលបានខ្ចីទាំងនោះចុងចម្លើយបានធ្វើការទូទាត់សងអស់ហើយ តែប្រាក់ដែលបានខ្ចីខាងលើនេះទេដែលចុងចម្លើយមិនទាន់បានសងនៅឡើយ។ ដោយមិនទាន់បានសងប្រាក់ទាំងអស់ខាងលើនោះ នៅថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៩ ចុងចម្លើយបានធ្វើកិច្ចសន្យាដើម្បីសងប្រាក់ជំពាក់នេះ ជាមួយដើមចោទ គឺ កិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៩។ ក្រោយមកដើម្បីបញ្ជាក់អំពីថ្ងៃ ខែ ឆ្នាំ ដែលបានខ្ចី និងចំនួនទឹកប្រាក់ដែលបានខ្ចីមិនទាន់បានសង ចុងចម្លើយក៏បានធ្វើការស្រង់ដោយកំណត់ដៃផ្ទាល់របស់ចុងចម្លើយ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៩ គឺត្រឹមត្រូវជាមួយនឹងបញ្ជីរបស់ដើមចោទ (ដូចគ្នា)។ តាមកិច្ចសន្យានេះ ចុងចម្លើយបានសន្យាសងប្រាក់ដើមចំនួន ៨៦.៥០០$ នៅថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៩ និងយល់ព្រមឱ្យការប្រាក់ចំនួន ៥% ក្នុងមួយខែ ប៉ុន្តែរហូតមកដល់បច្ចុប្បន្ន ចុងចម្លើយមិនដែលបានទូទាត់ការប្រាក់ និងប្រាក់ដើម មកឱ្យដើមចោទនោះទេ។ ចំពោះអង្គហេតុដែលជាមូលហេតុនៃការទាមទារមានដូចខាងក្រោម៖

ក-បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] ស្រីពេជ្រ សងប្រាក់ចំនួន ៨៦.៥០០$ (ប្រាំបីម៉ឺនប្រាំមួយពាន់ប្រាំរយ)ដុល្លារអាមេរិក ឱ្យដើមចោទឈ្មោះ [redacted] ចំប៉ា។

**ដោយហេតុថា:**

-ចុងចម្លើយបានខ្ចីប្រាក់ដើមចោទចំនួន ៨៦.៥០០$ (ប្រាំបីម៉ឺនប្រាំមួយពាន់ប្រាំរយ)ដុល្លារអាមេរិក ដូចមានបញ្ជាក់ក្នុង កិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៩។

-ចុងចម្លើយមិនបានអនុវត្តកាតព្វកិច្ចសងប្រាក់តាមការកំណត់ ថ្ងៃទី៣១ ខែ សីហា ឆ្នាំ២០១៩ តាមកិច្ចសន្យានោះទេ ។

-ពេលនេះ ការកំណត់រយៈពេលខ្ចីបានផុតការកំណត់ហើយ ចុងចម្លើយ នៅតែមិនព្រមសង ។

ខ-បង្គាប់ឱ្យចុងចម្លើយសងការប្រាក់ចំនួន ៥% ក្នុងមួយខែ គណនាលើប្រាក់ដើមចំនួន ៨៦.៥០០$



Scanned with CamScanner

ដោយចាប់គិតពីថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៩ រហូតដល់ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៩ ។

**ដោយហេតុថា:**

-តាមកិច្ចសន្យា ភាគីចុងចម្លើយបានព្រមព្រៀងឱ្យការប្រាក់ ៥% ក្នុងមួយខែ សម្រាប់អាណត្តិនៃកិច្ចសន្យាខ្ចីនេះ។

-ចុងចម្លើយ មិនបានបង់ការប្រាក់ចាប់ពីថ្ងៃដែលបានចុះកិច្ចសន្យាខ្ចីថ្ងៃទី១៦ ខែមីនា ឆ្នាំ ២០១៩ មក រហូតដល់ថ្ងៃបាត់បង់សិទ្ធិនៃការកំណត់រយៈពេលខ្ចី គឺថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៩ ។

គ-បង្គាប់ឱ្យចុងចម្លើយសងសំណងការខូចខាត ចំពោះការយឺតយ៉ាវ ដែលមិនបានសងប្រាក់ដើមតាមកាលកំណត់ចំនួន ២៧% ក្នុងមួយឆ្នាំ គណនាលើប្រាក់ដើមចំនួន ៨៦.៥០០$ ដោយចាប់គិតពីថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ២០១៩ រហូតដល់ថ្ងៃសងប្រាក់ដើមរួច ។

**ដោយហេតុថា:**

-ចុងចម្លើយមិនបានធ្វើការទូទាត់សងប្រាក់ដើមចំនួន ៨៦.៥០០$ តាមការកំណត់ នៅថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៩ តាមកិច្ចសន្យា ។

-ការដែរចុងចម្លើយមិនបានធ្វើការទូទាត់សងប្រាក់ដើមចំនួន ៨៦.៥០០$ ឱ្យដើមចោទតាមការកណត់នេះ បានឱ្យដើមចោទមានការខូចខាត ដោយមិនបានយកប្រាក់ដើមរបស់ខ្លួនមកចាត់ចែងដើម្បីទទួលបានប្រាក់ចំណេញបន្តទៀត ។

-បើប្រៀបធៀបទៅនិងការយកប្រាក់ទៅចងការតាមច្បាប់នោះ ក៏អាចទទួលបានការប្រាក់ ២៧% ក្នុងមួយឆ្នាំ ។

ឃ-បង្គាប់ឱ្យចុងចម្លើយសងសំណងការខូចខាតនិងជម្ងឺចិត្តចំនួន១២០.០០០.០០០៛(មួយរយម្ភៃលានរៀល)ឲ្យដើមចោទ។

**ដោយហេតុថា:**

-រឿងនេះគឺចុងចម្លើយជាអ្នកមានកំហុស និងជាអ្នកបង្កឡើង តាមរយៈនៃការរំលោភកិច្ចសន្យា ដោយមិនបានធ្វើការទូទាត់ប្រាក់ឲ្យដើមចោទតាមកិច្ចសន្យា ។

-អំពើរបស់ចុងចម្លើយនេះបានធ្វើឲ្យដើមចោទ មានការលំបាកក្នុងការចាត់ចែងរឿងនេះតាមផ្លូវច្បាប់ និងធ្វើឲ្យដើមចោទចំណាយពេលវេលា និងចំណាយថវិកា ជាសោហ៊ុយក្នុងការដំណើការរឿងនេះ ។

ង- ឱ្យចុងចម្លើយទទួលបន្ទុកប្រាក់ប្រដាប់ក្តី ។

**ដោយហេតុថា:**

-រឿងនេះសហចុងចម្លើយជាអ្នកមានកំហុស ដែលបង្កឱ្យកើតរឿងនេះឡើង។

ច- ប្រកាសអនុវត្តជាបណ្តោះអាសន្នលើចំណុច ក,ខ,គ ។

**ដោយហេតុថា:**

-ចំនួនទឹកប្រាក់ដែលដើមចោទទាមទារក្នុងចំណុច ក,ខ និងគ តាមច្បាប់ គឺជាប្រាក់ដែលចុងចម្លើយត្រូវតែសងមកឱ្យដើមចោទ ហើយពេលនេះដើមចោទត្រូវការទាមទារយកប្រាក់ទាំងអស់នេះពីចុងចម្លើយមកវិញ។

-តាមកិច្ចសន្យាចុងចម្លើយមានកាតព្វកិច្ច ត្រូវទូទាត់ប្រាក់ក្នុងចំណុច ក,ខ និងគ ឱ្យដើមចោទជាកំណត់ ។

-ការទុកប្រាក់ទាំងនេះនៅនឹងចុងចម្លើយ អាចនាំឱ្យមានបញ្ហាកើតឡើងចំពោះទំនាក់ទំនងគតិយុត្តិដល់ដើមចោទដែលជាម្ចាស់នៃទ្រព្យ។ ខាតបង់ប្រយោជន៍របស់ដើមចោទក្នុងការប្រើប្រាស់អាស្រ័យផលពីទ្រព្យរបស់ខ្លួន។

-ជាមធ្យោបាយដើម្បីឱ្យដើមចោទទទួលបានឆាប់នូវផលប្រយោជន៍ដែលជាទ្រព្យរបស់ខ្លួន។

-ការរង់ចាំដល់សេចក្តីសម្រេចចូលស្ថាពរនោះ អាចមានការយឺតយ៉ាវ ដែលជាហេតុធ្វើឱ្យរាំងស្ទះនូវការអនុវត្តសិទ្ធិរបស់ដើមចោទជាម្ចាស់ទ្រព្យ។

-ការពារដើមចោទកុំឱ្យមានការខូចប្រយោជន៍ស្របច្បាប់របស់ខ្លួន និងដើម្បីរក្សាតុល្យភាពជាមួយនឹងការប្តឹងឧបាស្រ័យ ទៅតុលាការជាន់ខ្ពស់។

ហើយខ្លួនសុំច្រានចោលសេចក្តីថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយត្រង់ចំណុចដូចខាងក្រោម៖

ក.ការដែលចុះកិច្ចសន្យាទទួលស្គាល់លើប្រាក់កម្ចីនោះ គឺជាការបង្ខិតបង្ខំ ចំណុចនេះខ្លួនសុំបញ្ជាក់ថា៖ កិច្ចសន្យានេះ ពុំមានការបង្ខិតបង្ខំទេ ការលើកឡើងរបស់មេធាវីចុងចម្លើយគ្រាន់តែជាលេសក្នុងការគេចវេសទេ។ ការស្រង់បញ្ជី គឺចុងចម្លើយជាអ្នកសរសេរដោយផ្ទាល់ដៃ ហើយគ្មានហេតុផលណាដែលកំណត់ ឬបញ្ជាក់ថាដើមចោទបង្ខិតបង្ខំនោះទេ។

ខ. អំពីភស្តុតាងរបស់ចុងចម្លើយ៖ ការលើកឡើងអំពីភស្តុតាងរបស់ចុងចម្លើយ គឺយកភស្តុតាងដែលបានទូទាត់មុនពេលនៃប្រាក់កម្ចីដែលដើមចោទបានទាមទារក្នុងរឿងនេះ គឺលើកយកភស្តុតាងដែលបានទូទាត់កាលពីក្នុងឆ្នាំ២០១៨ ដែលផ្ទុយនឹងការទាមទារក្នុងរឿងនេះ គឺទាមទារប្រាក់កម្ចីក្នុងឆ្នាំ២០១៩ ដូចនេះមិនអាចយកភស្តុតាងរបស់ចុងចម្លើយនេះមកធ្វើការបញ្ជាក់ពីការដែលចុងចម្លើយទូរទាត់ប្រាក់ឱ្យដើមចោទបានទេ ភស្តុតាងនេះជាភស្តុតាងរឿងចាស់។

គ. ចំពោះការលើកឡើងថា បំណុលទាំងនេះដើមចោទបូកការប្រាក់ចូលនោះ តាមពិតមិនមានទេ ជាក់ស្តែងណាស់ដូចក្នុងបញ្ជីស្រង់ដោយដៃរបស់ចុងចម្លើយខ្លួនឯង គឺបានបញ្ជាក់ពីពេលវេលាខ្ចី និងចំនួនប្រាក់ខ្ចី។ បើយើងពិនិត្យពីបញ្ជីនេះ គឺគ្មានហេតុផលណាបូកបញ្ចូលការប្រាក់នោះទេ។ សេចក្តីដូចបានបញ្ជាក់ខាងលើខ្លួនសុំច្រានចោលនូវសេចក្តីថ្លែងការណ៍របស់មេធាវីចុងចម្លើយទាំងស្រុង រួមទាំងភស្តុតាងរបស់ចុងចម្លើយ និងសុំតុលាការសម្រេចតាមការទាមទាររបស់ដើមចោទ។

ឃ.ចំពោះឡានដែលរឹបអូសនោះ តាមពិតគឺតុលាការបានរឹបអូសដោយមិនទាន់បានទូរទាត់មកឱ្យដើមចោទនៅឡើយទេ។

៤.លោក [redacted] ជាមេធាវីតំណាងឱ្យដោយអាណត្តិឱ្យចុងចម្លើយឈ្មោះ [redacted] ស្រីពេជ្រ បានថ្លែងការណ៍ថា ខ្លួនសុំច្រានចោលការទាមទាររបស់ដើមចោទគ្រប់ចំណុចទាំងអស់នៃការទាមទារខាងលើ ហើយខ្លួននៅតែរក្សាសេចក្តីថ្លែងការដូចមាននៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលចុះថ្ងៃទី០៧ ខែកក្កដា

ឆ្នាំ២០២០ ដដែល។ ហើយខ្លួនសូមធ្វើការបញ្ជាក់បន្ថែមថា កាលពីអំឡុងឆ្នាំ២០១៧ ទៅ ឆ្នាំ២០១៨ ចុងចម្លើយបានខ្ចីចងការប្រាក់រាប់លុយពីដើមចោទជាបន្តបន្ទាប់ពុំមានលិខិតស្នាមអ្វីជាលាយលក្ខណ៍អក្សរនោះទេ។ ចុងចម្លើយបានបង្វិលសងប្រាក់ដើមចោទ និងការប្រាក់ឱ្យដើមចោទជាបន្តបន្ទាប់។ នៅដើមឆ្នាំ២០១៩ ចុងចម្លើយខាតបង់ក្នុងមុខរបររកស៊ី មិនបានឡើងប្រាក់ដើម និងការប្រាក់ឱ្យដើមចោទតាមកាលកំណត់ទេ។ នៅចុងឆ្នាំ២០១៩ ដើមចោទបានបូកសរុបបញ្ជីបំណុលចាប់បង្ខំឱ្យចុងចម្លើយចុះហត្ថលេខាលើបំណុលសរុបចំនួន ៨ ៦០០០ (ប្រាំបីម៉ឺនប្រាំមួយពាន់)ដុល្លារអាមេរិក។ លុយរាប់នេះ គឺចុងចម្លើយបានឡើងការឱ្យដើមចោទក្នុងរយៈពេល ១៥ថ្ងៃម្តង ការប្រាក់មាន ២០% និង ៣០% ក្នុងមួយខែ។ កន្លងមកចុងចម្លើយបានបង់សងរំលស់ប្រាក់ដើមទៅឱ្យដើមចោទសរុបចំនួន ៥ ៤៤៣០(ប្រាំម៉ឺនបួនពាន់បួនរយសាមសិប)ដុល្លារអាមេរិក នៅសល់ប្រាក់ដើមចោទ ៣២ ០៧០(បីម៉ឺនពីរពាន់ចិតសិប)ដុល្លារអាមេរិក ប៉ុណ្ណោះ ដូចមានបញ្ជាក់ក្នុងពាក្យសុំដាក់ភស្តុតាងចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២០។ ហើយដើមចោទមិនទាន់បានដកបំណុលដែលចុងចម្លើយបានផ្ញើតាមវីង និងការរឹបអូសឡានរបស់ចុងចម្លើយចំនួន ០១គ្រឿង លក់បានចំនួន ៣០១០(បីពាន់ដប់)ដុល្លារអាមេរិក នោះទេ។

ក. ច្រានចោលការទាមទារប្រាក់ដើមចំនួន ៨ ៦០០០(ប្រាំបីម៉ឺនប្រាំមួយពាន់)ដុល្លារអាមេរិក ទទួលស្គាល់ប្រាក់ដើមចំនួន ៣២ ០៧០(បីម៉ឺនពីរពាន់ចិតសិប)ដុល្លារអាមេរិក។

ខ. ច្រានចោលការទាមទារការប្រាក់ចំនួន ៥% ក្នុងមួយខែ សុំគិតការប្រាក់តាមច្បាប់ ៥%ក្នុងមួយឆ្នាំលើប្រាក់ដើមចំនួន ៣២ ០៧០(បីម៉ឺនពីរពាន់ចិតសិប)ដុល្លារអាមេរិក។

គ.ច្រានចោលការទាមទារសំណងខូចខាតលើការប្រាក់យឺតយ៉ាវដែលដើមចោទបានទាមទារចំនួន២៧% ក្នុងមួយឆ្នាំ។

ឃ. ច្រានចោលការទាមទារសំណងជម្ងឺចិត្ត ដោយហេតុថាដើមចោទបានទាមទារការប្រាក់ហើយ។

ង.ច្រានចោលការទាមទារឱ្យបង់ប្រាក់ប្រដាប់ក្តី។

ច.ច្រានចោលការទាមទារឱ្យប្រកាសអនុវត្តជាបណ្តោះអាសន្ន ដោយហេតុថា ចុងចម្លើយគ្មានការទទួលស្គាល់បំណុលដែលដើមចោទបានទាមទារ ឯកសារខ្ចីប្រាក់របស់ដើមចោទគ្មានភាពជាក់លាក់ឡើយ សូមទុកឱ្យតុលាការជាន់ខ្ពស់សម្រេចសិន។

**៥.ចំណុចវិវាទ៖**

-ដើមចោទអះអាងថាចុងចម្លើយជំពាក់ប្រាក់ដើមចំនួន ៨ ៦០០០(ប្រាំបីម៉ឺនប្រាំមួយពាន់)ដុល្លារអាមេរិក ប៉ុន្តែចុងចម្លើយអះអាងថានៅជំពាក់ត្រឹមតែ ៣២ ០៧០(បីម៉ឺនពីរពាន់ចិតសិប)ដុល្លារអាមេរិក ប៉ុណ្ណោះ។

-ដើមចោទទាមទារការប្រាក់ចំនួន ៥%ក្នុងមួយខែ គិតចាប់ពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៩ រហូតដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៩ លើប្រាក់ដើមចំនួន ៨៦ ៥០០(ប្រាំបីម៉ឺនប្រាំមួយពាន់ប្រាំរយ)ដុល្លារអាមេរិក ប៉ុន្តែចុងចម្លើយសុំគិតការប្រាក់តាមច្បាប់ ៥%ក្នុងមួយឆ្នាំ លើប្រាក់ដើមចំនួន ៣២ ០៧០(បីម៉ឺនពីរពាន់ចិតសិប)ដុល្លារអាមេរិក។



Scanned with CamScanner

-ដើមចោទទាមទារសំណងការខូចខាត ចំពោះការយឺតយ៉ាវចំនួន ២៧% ក្នុងមួយឆ្នាំ គណនាលើប្រាក់ដើមចំនួន ៨៦ ៥០០ ដុល្លារអាមេរិក ដោយចាប់គិតពីថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៩ រហូតដល់ថ្ងៃសងប្រាក់ដើមគ្រប់ចំនួន ប៉ុន្តែចុងចម្លើយសុំច្រានចោល។

- ការទាមទារសំណងការខូចខាត និងជម្ងឺចិត្តចំនួន១២០.០០០.០០០ (មួយរយម្ភៃលាន)រៀល។

-បន្ទុកប្រាក់ប្រដាប់ក្ដី ។

-ប្រកាសអនុវត្តបណ្ដោះអាសន្ន។

៦.ចំណុចគ្មានវិវាទ ៖ គ្មាន។

## II.ការពិនិត្យភស្តុតាង

**១- ភស្តុតាងជាឯកសាររបស់ដើមចោទ៖**

១.១. កិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៩ រវាងសហដើមចោទឈ្មោះ [redacted] ពៅ និងចុងចម្លើយឈ្មោះ [redacted] ស្រីពេជ្រ ទីកប្រាក់ចំនួន ៨៦ ៥០០(ប៉ែតសិបប្រាំមួយពាន់ប្រាំរយ)ដុល្លារអាមេរិក។

១.២.កិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៩ រវាងសហដើមចោទឈ្មោះ [redacted] ចំប៉ា និងចុងចម្លើយឈ្មោះ [redacted] ស្រីពេជ្រ ទីកប្រាក់ចំនួន ៨៦ ៥០០(ប៉ែតសិបប្រាំមួយពាន់ប្រាំរយ)ដុល្លារអាមេរិក។

១.៣.លិខិតបញ្ជាក់លើអចលនវត្ថុលេខ ៤៤៣០ ដនសស.សរ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៩ របស់ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តសៀមរាប។

១.៤.ដីកាសម្រេចរក្សាការពារ លេខ ២១២ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តសៀមរាប ដែលបានសម្រេចរឹបអូសនូវដីមួយកន្លែង និងរថយន្តមួយគ្រឿង ពាក់ព័ន្ធនឹងប្រាក់កម្ចីចំនួន ៨៦ ៥០០ (ប៉ែតសិបប្រាំមួយពាន់ប្រាំរយ) ដុល្លារអាមេរិក រវាងដើមចោទឈ្មោះ [redacted] ចំប៉ា និងចុងចម្លើយឈ្មោះ [redacted] ស្រីពេជ្រ។

១.៥.លិខិតផ្ទុកផ្ដាក់ឱ្យចុះបញ្ជីអំពីការរឹបអូស លេខ ១៣១ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៩ របស់ក្រុមក្រឡាបញ្ជីសាលាដំបូងខេត្តសៀមរាប លើដីមួយកន្លែងពាក់ព័ន្ធនឹងប្រាក់កម្ចីចំនួន ៨៦ ៥០០ (ប៉ែតសិបប្រាំមួយពាន់ប្រាំរយ) ដុល្លារអាមេរិក រវាងដើមចោទឈ្មោះ [redacted] ចំប៉ា និងចុងចម្លើយឈ្មោះ [redacted] ស្រីពេជ្រ។

**២.ភស្តុតាងជាឯកសាររបស់ចុងចម្លើយ៖**

២.១.ឯកសារផ្ទេរប្រាក់តាមរយៈគណនីធនាគារ ថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៨ ប្រាក់ចំនួន ៥ ១៥០ (ប្រាំពាន់មួយរយហាសិប)ដុល្លារអាមេរិក លេខកូដប្រតិបត្តិការ ៨០៩៨១៣៨៤១។

២.២.ឯកសារផ្ទេរប្រាក់តាមរយៈគណនីធនាគារ ថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៨ ប្រាក់ចំនួន ៤ ០០០ (បួនពាន់)ដុល្លារអាមេរិក លេខកូដប្រតិបត្តិការ ៨១១៤៦៣៦១៧។

២.៣.ឯកសារផ្ទេរប្រាក់តាមរយៈគណនីធនាគារ ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៨ ប្រាក់ចំនួន ៧ ០០០ (ប្រាំពីរពាន់)ដុល្លារអាមេរិក លេខកូដប្រតិបត្តិការ ៨៩២៥០២៦៣៨។



Scanned with CamScanner

២.៤.ឯកសារផ្ទេរប្រាក់តាមរយៈគណនីធនាគារ ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៨ ប្រាក់ចំនួន ៤ ៥០០ (បួនពាន់ប្រាំរយ)ដុល្លារអាមេរិក លេខកូដប្រតិបត្តិការ ៩០០៩៣០២៥៨។

២.៥.ឯកសារផ្ទេរប្រាក់តាមរយៈគណនីធនាគារ ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៨ ប្រាក់ចំនួន ៦ ៦៧០ (ប្រាំមួយពាន់ប្រាំមួយរយចិតសិប)ដុល្លារអាមេរិក លេខកូដប្រតិបត្តិការ ៩៣១២៧០៨១៣។

២.៦.ឯកសារផ្ទេរប្រាក់តាមរយៈគណនីធនាគារ ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៩ ប្រាក់ចំនួន ៩ ០០០ (ប្រាំបួនពាន់)ដុល្លារអាមេរិក លេខកូដប្រតិបត្តិការ ១០៥៨៧៥៨៤២៧។

២.៧.ឯកសារផ្ទេរប្រាក់តាមរយៈគណនីធនាគារ ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៩ ប្រាក់ចំនួន ១០ ០០០ (មួយម៉ឺន)ដុល្លារអាមេរិក លេខកូដប្រតិបត្តិការ ១០៧៥១៩០២០៦។

២.៨.ឯកសារផ្ទេរប្រាក់តាមរយៈគណនីធនាគារ ថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៩ ប្រាក់ចំនួន ៥ ០០០ (ប្រាំពាន់)ដុល្លារអាមេរិក លេខកូដប្រតិបត្តិការ ១០៨៦៦៧២២៧៣។

២.៩.ឯកសារផ្ញើប្រាក់តាមរយៈវីងវេរលុយ ថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៩ ប្រាក់ចំនួន ១០០ (មួយរយ)ដុល្លារអាមេរិក ។

៣.ការសាកសួរសាក្សី-គ្មាន

## សំអាងហេតុ

ផ្អែកតាមលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់ និងការពិនិត្យភស្តុតាង តុលាការយល់ឃើញថា៖

១-តាមកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៩ និងកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៩ រវាងសហដើមចោទឈ្មោះ [redacted]ពៅ និងឈ្មោះ [redacted] ចំប៉ា និងចុងចម្លើយឈ្មោះ [redacted] ស្រីពេជ្រ បញ្ជាក់បានថា ចុងចម្លើយឈ្មោះ [redacted] ស្រីពេជ្រ ពិតជាបានខ្ចីប្រាក់សហដើមចោទសរុបចំនួន ៨៦ ៥០០ (ប្រាំបីម៉ឺនប្រាំមួយពាន់ប្រាំរយ)ដុល្លារអាមេរិក ប្រាកដមែន។

២-ដើមចោទប្ដឹងទាមទារប្រាក់ដើមចំនួន ៨៦ ៥០០(ប្រាំបីម៉ឺនប្រាំមួយពាន់ប្រាំរយ)ដុល្លារអាមេរិក ប៉ុន្តែមេធាវីចុងចម្លើយបានបដិសេធថា កន្លងមកកូនក្ដីរបស់ខ្លួនបានបង់សងរំលស់ប្រាក់ដើមទៅឱ្យដើមចោទសរុបចំនួន ៥៤ ៤៣០(ប្រាំម៉ឺនបួនពាន់បួនរយសាមសិប)ដុល្លារអាមេរិក រួចហើយ នៅសល់ប្រាក់ដើមត្រឹមតែ ៣២ ០៧០ (បីម៉ឺនពីរពាន់ចិតសិប)ដុល្លារអាមេរិក ប៉ុណ្ណោះ ដូចមានបញ្ជាក់ក្នុងភស្តុតាងជាឯកសារដែលខ្លួនបានដាក់ជូនឱ្យតុលាការពិនិត្យខាងលើ។ តាមការពិនិត្យទៅលើភស្តុតាងជាឯកសារសងប្រាក់របស់ចុងចម្លើយទាំងអស់ខាងលើ និងកិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៩ និងកិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៩ ដែលដាក់ដោយដើមចោទ ឃើញថា កាលបរិច្ឆេទនៃឯកសារសងប្រាក់ទាំងអស់របស់ចុងចម្លើយខាងលើ គឺជាការសងប្រាក់មុនកាលបរិច្ឆេទបង្កើតកិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៩ និងកិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៩ ហើយឯកសារសងប្រាក់ទាំងអស់របស់ចុងចម្លើយ ត្រូវបានដើមចោទអះអាងថាជាឯកសារសងបំណុលចាស់ដែលបានខ្ចីកាលអំឡុងឆ្នាំ២០១៨ ប៉ុណ្ណោះ ចំណែកប្រាក់ដែលដើមចោទទាមទារ

ខាងលើនេះ គឺជាប្រាក់កម្ចីក្នុងឆ្នាំ២០១៩។ តាមកិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៩ និងកិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៩ និងការអះអាងរបស់ដើមចោទ មានភាពសមស្របអាចឱ្យតុលាការជឿបានថា ចុងចម្លើយពិតជានៅជំពាក់ប្រាក់ដើមចោទចំនួន ៨៦ ៥០០(ប្រាំបីម៉ឺនប្រាំមួយពាន់ប្រាំរយ)ដុល្លារអាមេរិកប្រាកដមែន ហេតុនេះគប្បីតុលាការសម្រេចការទាមទាររបស់ដើមចោទ។

៣-ដើមចោទទាមទារឱ្យចុងចម្លើយសងការប្រាក់ចំនួន **៥%** (ប្រាំភាគរយ) ក្នុងមួយខែ គណនាលើប្រាក់ដើមចំនួន ៨៦ ៥០០(ប្រាំបីម៉ឺនប្រាំមួយពាន់ប្រាំរយ)ដុល្លារអាមេរិក ដោយចាប់គិតពីថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៩ រហូតដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៩ ដោយសំអាងទៅលើការព្រមព្រៀងដែលមាននៅក្នុងកិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៩។ ការទាមទារត្រង់ចំណុចនេះ ត្រូវបានមេធាវីចុងចម្លើយបដិសេធដោយសុំគិតការប្រាក់តាមច្បាប់ ៥%ក្នុងមួយឆ្នាំ លើប្រាក់ដើមចំនួន **៣២ ០៧០(បីម៉ឺនពីរពាន់ចិតសិប)ដុល្លារអាមេរិក**។ តាមការពិនិត្យទៅលើកិច្ចសន្យាខ្ចីប្រាក់ ឃើញថាគូភាគីបានព្រមព្រៀងកំណត់អត្រាការប្រាក់នៅក្នុងកិច្ចសន្យារួចហើយ ហេតុនេះតុលាការមិនអាចសម្រេចតាមការស្នើសុំរបស់មេធាវីចុងចម្លើយដែលសុំគិតការប្រាក់តាមច្បាប់ចំនួន **៥%ក្នុងមួយឆ្នាំ** បានទេ ប៉ុន្តែការព្រមព្រៀងរបស់គូភាគីនៅក្នុងកិច្ចសន្យាដែលបានកំណត់អំពីអត្រាការប្រាក់ចំនួន **៥%ក្នុងមួយខែ** គឺស្មើនឹងអត្រាការប្រាក់ចំនួន **៦០%ក្នុងមួយឆ្នាំ** ដែលការព្រមព្រៀងនេះគឺលើសពីអត្រាការប្រាក់ដែលច្បាប់បានកម្រិតយ៉ាងច្រើន។ យោងតាមមាត្រា **៥៨៥ កថាខណ្ឌទី២ និងទី៣** នៃក្រមរដ្ឋប្បវេណី បានហាមមិនឱ្យភាគីកំណត់ការប្រាក់លើសពីអត្រាការប្រាក់ដែលត្រូវបានកម្រិតឡើយ ហើយប្រសិនបើភាគីបានកំណត់អត្រាការប្រាក់លើសពីអត្រាការប្រាក់ដែលត្រូវបានកម្រិតភាគដែលលើសនោះត្រូវចាត់ទុកជាមោឃៈ រីឯអ្នកខ្ចីមានករណីកិច្ចសងតែចំពោះការប្រាក់ដែលត្រូវគណនាតាមអត្រាការប្រាក់ដែលត្រូវបានកម្រិតប៉ុណ្ណោះ។ ផ្អែកតាមប្រការ ១ នៃប្រកាសស្តីពីអត្រាការប្រាក់ដែលត្រូវបានកម្រិត លេខ ១២៨ ក.យ.ប្រក/១១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ របស់ទីស្តីការក្រសួងយុត្តិធម៌ និងប្រការ ៤ នៃប្រកាសស្តីពីការកំណត់ពិដានអត្រាការប្រាក់ឥណទាន លេខ **ធ៧ ០១៧ ១០៩ ប្រ ក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៧** របស់ធនាគារជាតិនៃកម្ពុជា បានចែងកំណត់អត្រាការប្រាក់ដែលត្រូវបានកម្រិតមិនឱ្យលើសពី ១៨% ក្នុងមួយឆ្នាំ ហេតុនេះគប្បីតុលាការសម្រេចឱ្យចុងចម្លើយសងការប្រាក់ទៅឱ្យដើមចោទចំនួន **១៨%ក្នុងមួយឆ្នាំ** ។

៤-ដើមចោទទាមទារឱ្យចុងចម្លើយសងសំណងការខូចខាត ចំពោះការយឺតយ៉ាវដែលមិនបានសងប្រាក់ដើមតាមការកំណត់ ចំនួន **២៧% ក្នុងមួយឆ្នាំ** គណនាលើប្រាក់ដើមចំនួន **៨៦ ៥០០ ដុល្លារអាមេរិក** ដោយចាប់គិតពីថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៩ រហូតដល់ថ្ងៃសងប្រាក់ដើមគ្រប់ចំនួន។ យោងតាមមាត្រា ៣៩៨ នៃក្រមរដ្ឋប្បវេណី ក្នុងករណីដែលចុងចម្លើយមិនបានអនុវត្តកាតព្វកិច្ចតាមពេលកំណត់ ដើមចោទអាចទាមទារសំណងនៃការខូចខាតដែលកើតឡើងដោយសារការមិនអនុវត្តកាតព្វកិច្ចនោះបាន។ តាមការពិនិត្យទៅលើកិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៩ និងកិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៩ ឃើញថាគូភាគីបានកំណត់អត្រាការប្រាក់ចំនួន **៥%ក្នុងមួយខែ** និងឱ្យចុងចម្លើយសងប្រាក់នៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៩ ប៉ុន្តែនៅក្នុងកិច្ចសន្យានោះគូភាគីពុំបានកំណត់ជាមុនអំពីសំណងការខូចខាតក្នុងករណីដែលចុងចម្លើយមិនបានអនុវត្ត

កាតព្វកិច្ចសងប្រាក់តាមពេលកំណត់នោះទេ។ យោងតាមមាត្រា ១៧ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី និងប្រការ២ នៃប្រកាសស្តីពីអត្រាការប្រាក់ដែលត្រូវបានកម្រិត លេខ ១២៨ ក.យ.ប្រក/១១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ របស់ទីស្តីការក្រសួងយុត្តិធម៌ ឃើញថា ក្នុងករណីមិនមានការសន្យាពិសេសណាមួយស្តីពីប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ចក្នុងកិច្ចសន្យាខ្ចីបរិភោគដែលមានកម្មវត្ថុជាប្រាក់ដែលភ្ជាប់ជាមួយនឹងការប្រាក់ទេនោះ ត្រូវចាត់ទុកថាប្រាក់សំណងនៃការខូចខាតចំពោះការយឺតយ៉ាវនោះជាការប្រាក់ក្នុងកម្រិត ១៨%ក្នុងមួយឆ្នាំ ហេតុនេះដោយកិច្ចសន្យារបស់គូភាគីគឺជាកិច្ចសន្យាខ្ចីប្រាក់ដែលភ្ជាប់ជាមួយនឹងការប្រាក់ ហើយគូភាគីមិនបានកំណត់ជាមុនអំពីសំណងការខូចខាតក្នុងករណីដែលចុងចម្លើយមិនបានអនុវត្តកាតព្វកិច្ចសងប្រាក់តាមពេលកំណត់ គប្បីតុលាការសម្រេចឱ្យចុងចម្លើយសងការខូចខាតចំពោះការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ចទៅឱ្យដើមចោទតាមច្បាប់ក្នុងអត្រាការប្រាក់ចំនួន ១៨%ក្នុងមួយឆ្នាំ។

៥-ដើមចោទទាមទារឱ្យចុងចម្លើយសងសំណងការខូចខាត និងជម្ងឺចិត្តចំនួន **១២០.០០០.០០០៛ (មួយរយម្ភៃលាន)រៀល** ការទាមទារនេះពុំមានភាពសមស្របនោះទេ ដោយហេតុថាដើមចោទបានទាមទារការប្រាក់ និងប្រាក់សំណងនៃការខូចខាតចំពោះការយឺតយ៉ាវដែលជាតម្លៃតបពីការខូចខាតក្នុងករណីដែលចុងចម្លើយមិនអនុវត្តកាតព្វកិច្ចខាងលើរួចហើយ ហេតុនេះគប្បីតុលាការសម្រេចច្រានចោលការទាមទារជម្ងឺចិត្តរបស់ដើមចោទ។

៦- ដើមចោទទាមទារឱ្យចុងចម្លើយទទួលបន្ទុកប្រាក់ប្រដាប់ក្តី ការទាមទារនេះមានភាពសមស្របតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ហេតុនេះគប្បីតុលាការសម្រេចតាមការទាមទាររបស់ដើមចោទ។

៧-ដើមចោទទាមទារឱ្យតុលាការប្រកាស សាលក្រមនេះមានអានុភាពអនុវត្តបណ្តោះអាសន្នលើចំណុចប្រាក់ដើម, ការប្រាក់ និងសំណងការខូចខាតចំពោះការយឺតយ៉ាវ ការទាមទារចំណុចនេះតុលាការយល់ឃើញថាពុំមានភាពចាំបាច់ដែលនាំឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ដើមចោទធ្ងន់ធ្ងរនោះទេ ម្យ៉ាងទៀតចុងចម្លើយក៏បានធ្វើការតវ៉ាទៅលើចំនួនប្រាក់ដើមដែលនៅជំពាក់ផងដែរ គប្បីតុលាការសម្រេចច្រានចោលការទាមទាររបស់ដើមចោទត្រង់ចំណុចនេះ។

**សេចក្តីសម្រេចបញ្ចប់**

**១**-ឱ្យចុងចម្លើយឈ្មោះ [redacted] **ស្រីពេជ្រ** ដែលមានលោក [redacted] **គល** ជាមេធាវីតំណាងដោយអាណត្តិ សងប្រាក់ទៅឱ្យសហដើមចោទឈ្មោះ [redacted] **ចំប៉ា** និងម្តាយឈ្មោះ [redacted] **ពៅ** ដែលមានលោក ស្រី **ជា ស្រីហ៊ុច** ជាមេធាវីតំណាងដោយអាណត្តិ ដូចខាងក្រោម ៖

**ក**-ប្រាក់ដើមចំនួន **៨៦ ៥០០$(ប្រាំបីម៉ឺនប្រាំមួយពាន់ប្រាំរយ)ដុល្លារអាមេរិក។**

**ខ**-ការប្រាក់ក្នុងអត្រាចំនួន **១៨% (ដប់ប្រាំបីភាគរយ)** ក្នុងមួយឆ្នាំ គណនាលើប្រាក់ដើមចំនួន ៨៦ ៥០០(ប្រាំបីម៉ឺនប្រាំមួយពាន់ប្រាំរយ)ដុល្លារអាមេរិក ចាប់គិតពីថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៩ រហូតដល់ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៩។



Scanned with CamScanner

ឝ-សងសំណងការខូចខាតចំពោះការយឺតយ៉ាវ ដែលមិនបានសងប្រាក់ដើមតាមកាលកំណត់ ចំនួន **១៨%** ក្នុងមួយឆ្នាំ គណនាលើប្រាក់ដើមចំនួន **៨៦ ៥០០(ប៉ែតសិបប្រាំមួយពាន់ប្រាំរយ) ដុល្លារអាមេរិក** គិតចាប់ពីថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៩ រហូតដល់ថ្ងៃសងប្រាក់ដើមគ្រប់ចំនួន។

២-ច្រានចោលការទាមទារសំណងការខូចខាត និងជម្ងឺចិត្តរបស់ដើមចោទ។

៣-ច្រានចោលការទាមទាររបស់ដើមចោទ ដែលប្តឹងសុំឱ្យលោការចេញសាលក្រមប្រកាសអនុវត្តជាបណ្តោះអាសន្នត្រង់ចំណុច ១-ក, ១-ខ, ១-គ នៃសេចក្តីសម្រេចបញ្ចប់ខាងលើ។

៤-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សហចុងចម្លើយ។

សាលក្រមនេះ បានបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២០ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២០ ចំពោះមុខលោកស្រី [redacted] មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទឈ្មោះ [redacted] ចំប៉ា និងឈ្មោះ [redacted] ពៅ និងលោក [redacted] ពល ជាមេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយឈ្មោះ [redacted] ស្រីពេជ្រ ។ ទុកសិទ្ធិឱ្យប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ចៅក្រម**

ហត្ថលេខា និងត្រា [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃពុធ ១២កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
សៀមរាប, ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២០
**ក្រឡាបញ្ជី**

[redacted]

បានឃើញ
**ចៅក្រម**

[redacted]